TUKTUK



# ផ្ទះរបស់សុខា

# Sokha’s House

Written by TukTuk

Illustrated by Kaho Yamada



និពន្ធដោយ TukTuk

រូបភាពដោយ Kaho Yamada



ជម្រាបសួរ! ខ្ញុំឈ្មោះសុខា។ ខ្ញុំនឹងប្រាប់អ្នកអំពីផ្ទះរបស់ខ្ញុំ!
តើអ្នកឃើញផ្ទះមួយនៅពីក្រោយខ្ញុំទេ? នោះជាផ្ទះរបស់ខ្ញុំ។



# ២



នៅផ្ទះរបស់ខ្ញុំមានដើមដូង។ តើមានដើមដូងចំនួនប៉ុន្មាន? ១ ២! មាន២ដើម។
នៅពេលដែលខ្ញុំស្រេកទឹក បងប្រុសច្បងរបស់ខ្ញុំនឹងឡើងទៅបេះដូងឱ្យខ្ញុំផឹក។

# ៣



នៅពីមុខផ្ទះរបស់ខ្ញុំ មានពាងទឹក។ តើមានពាងទឹកចំនួនប៉ុន្មាន? ១ ២ ៣! មាន៣។
ពួកយើងប្រើប្រាស់វា នៅពេលដែលពួកយើងងូតទឹក ចម្អិនអាហារនិងធ្វើអ្វីផ្សេងទៀត។

# ៤



មើលន៎! នៅជុំវិញពាងទឹកមានកូនឆ្កែ។តើមានកូនឆ្កែចំនួនប៉ុន្មាន?
១ ២ ៣ ៤! មាន៤ក្បាល។ ពួកវាទើបតែកើតកាលពីខែមុនទេ។ តើពួកវាស្អាតដែរទេ?




មើលទៅនុ៎ះ! មានកូនមាន់ទៀតផង។ តើមានកូនមាន់ចំនួនប៉ុន្មាន? ១ ២ ៣ ៤ ៥! មាន៥ក្បាល។
ចេបៗ ចេបៗ ចេបៗ! តើម៉ែនៅទីណា? កូនមាន់កំពុងតែរកមេរបស់ពួកវា។

# ៦



តើអ្នកឃ្លានមែនទេ? កុំបារម្ភអីណា! ពួកយើងមានដើមស្វាយចំនួន១ដើម។
តោះទៅមើលថា តើមានផ្លែស្វាយចំនួនប៉ុន្មានផ្លែដែលយើងអាចញ៉ាំបាន?

# ៦



តោះរាប់ជាមួយគ្នា ១ ២ ៣ ៤ ៥ ៦! មាន៦ផ្លែ។



៧



ពួកយើងថែមទាំងមានដើមចេកចំនួន១ដើមទៀតផង។
តើមានផ្លែចេកចំនួនប៉ុន្មានផ្លែដែលយើងអាចញ៉ាំបាន?



# ៧



តោះរាប់ជាមួយគ្នា ១ ២ ៣ ៤ ៥ ៦ ៧! មាន៧ផ្លែ។




ម៉ែនៅទីនេះ! គាត់ត្រឡប់មកពីធ្វើការវិញហើយ។ គាត់មានហាងលក់ចេកចៀនមួយ។
ថ្ងៃនេះ គ្រប់គ្នានឹងមកលេងពួកយើង ដូច្នេះគាត់បានយកចេកចៀនខ្លះៗមកផ្ទះ។




តើមានចេកចៀនចំនួនប៉ុន្មាន? ១ ២ ៣ ៤ ៥ ៦ ៧ ៨! យេ៎! មាន៨ដុំ។



លោកយាយបានមកដល់ផ្ទះ! សួស្តីសុខា! តើចៅចូលចិត្តនំអន្សមមែនទេ?
លោកយាយបានទិញនំអន្សមផ្ញើចៅ។ យ៉េ! អរគុណលោកយាយ។

# ៩



តើមាននំអន្សមចំនួនប៉ុន្មាន? ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩! មាន៩នំ។

# ១៧



ថ្ងៃនេះ គ្រួសាររបស់ខ្ញុំបានមកជួបជុំគ្នា។ លោកយាយនិងលោកតា ម៉ាក់និងប៉ា
បងស្រីនិងបងប្រុស ខ្ញុំនិងប្អូនប្រុសពៅ ហើយបន្ទាប់មកគឺបងប្អូនជីដូនមួយចំនួនពីរនាក់ទៀត។

# ១០



តើទាំងអស់គ្នាមានចំនួនប៉ុន្មាននាក់? ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០!
មានចំនួន ១០នាក់។ ពួកយើងញ៉ាំអាហារពេលល្ងាចជុំគ្នាយ៉ាងសប្បាយរីករាយ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

TUKTUK

Rotary

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែលមិនរកប្រាក់ចំណេញនិងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍។

អង្គការ R4C បានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្រប ទៅនឹងកម្មវិធីសិក្សារបស់ក្រសួងអប់រំនិងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រ ដើម្បីទទួលបានធនធានបង្រៀន៖ https//rermork.org/

ទទួលបានព័ត៌មានបន្ថែម

មូលនិធិផ្តល់ដោយអង្គការTukTukនិងសមាគមរ៉ូតារីក្លឹប។

សៀវភៅរឿងនេះគឺនិពន្ធដោយ TukTuk និងគូរដោយ Kaho Yamada។
ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកស្ម័គ្រចិត្តនិងបុគ្គលិកទាំងអស់នៅក្នុងអង្គការ ជាមួយនឹងRoberta Dahl ដែលបានចូលរួមកែសម្រួលនិងបកប្រែសៀវភៅរឿងនេះ។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្រៀន